# ការប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មានឥទ្ធិពលប្រព្រឹត្តិកម្ម (PSM) ដើម្បីបង្កើតគំរូតាងប្រៀបធៀបក្នុងការវាយតម្លៃគម្រោង៖ ករណីសិក្សានៃគម្រោងដឹកជញ្ជូន[១]

## សេចក្តីផ្តើម

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ការគាំទ្រដល់មហាអនុតំបន់មេគង្គ (GMS) តាំងតែពីពេលបង្កើតឡើងក្នុងឆ្នាំ១៩៩២ ដោយប្រទេសកម្ពុជា ចិន ឡាវ ភូមា ថៃ និងវៀតណាម ក្នុងបំណងពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចទៅវិញទៅមក ។ នៅឆ្នាំ២០០២ ប្រទេស GMS ខាងលើ បានអនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្រ GMS ២០០២-១២ ដែលមានចែងពីរបៀបវារៈអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយមួយ និងបានគូសបញ្ជាក់ពី តម្រូវការធ្វើសហប្រតិបត្តិការបង្កើតគោលនយោបាយ និងកម្មវិធីនានា ជាបន្ថែមលើទំនាក់ទំនងខាងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីលើកស្ទួយកំណើនប្រកបដោយសមធម៌ និងមិនខូចខាតដល់បរិស្ថាន ។

ការស្តារជួសជុល និងកែលំអប្រព័ន្ធដឹកជញ្ជូនក្នុងប្រទេស GMS គឺជាវិស័យមួយ ក្នុងចំណោមវិស័យសហប្រតិបត្តិការជាអាទិភាពទាំង ៩ ដែលបានកំណត់ឡើង[២] ។ គម្រោងច្រករបៀងនៅតំបន់ឆ្នេរភាគខាងត្បូងនៃ GMS (GMS-SCC) បានជួយស្តារឡើងវិញនូវផ្លូវជាតិលេខ៣៣ នៅកម្ពុជា និងផ្លូវមួយកំណាត់ទៀតនៅវៀតណាមខាងត្បូង ។ គម្រោងនេះរំពឹងថា នឹងជះឥទ្ធិពលយ៉ាងច្រើន ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការទទួលបានឱកាសការងារ ទីផ្សារ និងសេវាសង្គមកាន់តែប្រសើរ ។

គម្រោង GMS-SCC បានដំណើរការគួរឲ្យកត់សម្គាល់ ។ ប៉ុន្តែការវាយតម្លៃពាក់កណ្តាលអាណត្តិ លើក្របខ័ណ្ឌយុទ្ធសាស្ត្របង្ហាញថា ទំហំ និងវិសាលភាពជាក់លាក់ ដែលគម្រោងបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងកែលំអសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចផ្សេងទៀត មិនអាចវាស់បានទេ ប្រសិនបើមិនមានព័ត៌មានមូលដ្ឋានសព្វគ្រប់លើគម្រោង សម្រាប់ធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើជំនួយ ។ ការប៉ាន់ស្មានបែបសាមញ្ញមួយអំពីផលប៉ះពាល់នៃអន្តរាគមន៍ គឺ ការប្រៀបធៀបពីលទ្ធផលទាក់ទង រវាងក្រុមរងប្រព្រឹត្តិកម្ម (ប្រជាជនក្នុងតំបន់អនុវត្តគម្រោង) ជាមួយនឹងក្រុមមិនរងប្រព្រឹត្តិកម្ម (ប្រជាជនក្នុងតំបន់មិនអនុវត្តគម្រោង និងជាក្រុមសម្រាប់ប្រៀបធៀប) ។ ប៉ុន្តែលទ្ធផលរកឃើញខុសប្លែកគ្នារវាងក្រុមទាំងពីរនេះ មិនអាចជឿជាក់បានទេ ប្រសិនបើមិនលុបបំបាត់ចោលភាពលំអៀងនានា (Ravallion 2001) ។ Propensity score matching (PSM) ជាបច្ចេកទេសស្ថិតិមួយ ដែលអាចឲ្យអ្នកស្រាវជ្រាវរកឃើញកត្តាលំអៀងក្នុងក្រុមទាំងពីរ ដើម្បីលុបបំបាត់វាចោល ។

ការសិក្សានេះ សំដៅវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃគម្រោង GMS-SCC នៅកម្ពុជា ដើម្បី (១) រៀបចំ និងបង្កើតទិន្នន័យគោលពេញលេញមួយ និងបកស្រាយលើសូចនាករពាក់ព័ន្ធមួយចំនួន (២) វាយតម្លៃ និងផ្តល់ទិន្នន័យមូលដ្ឋានសព្វគ្រប់ សម្រាប់វាយតម្លៃនៅតំបន់អនុវត្តគម្រោង និងតំបន់មិនអនុវត្តគម្រោង ដែលបានជ្រើសរើស (សម្រាប់ប្រៀបធៀប) និង (៣) ប្រើវិធីសាស្ត្រ PSM បង្កើតក្រុមរងប្រព្រឹត្តិកម្ម (treatment group) និងក្រុមមិនរងប្រព្រឹត្តិកម្ម (ទុកប្រើជាក្រុមសម្រាប់ប្រៀបធៀប) ។

## វិធីសាស្ត្រស្រាវជ្រាវ

អង្កេតគ្រួសារមួយបានធ្វើឡើង ដើម្បីកំណត់សូចនាករមូលដ្ឋាននានា ។ គ្រួសារគំរូតាងចែកចេញជា ២ក្រុម ទៅតាមទីតាំងភូមិសាស្ត្រ គឺ តំបន់ក្នុងគម្រោង (ក្រុមក្នុងគម្រោង) និងតំបន់ក្រៅគម្រោង (ក្រុមក្រៅគម្រោង) ។ តំបន់ក្នុងគម្រោង ត្រូវបានជ្រើសរើសក្នុងចំងាយ ៥គីឡូម៉ែត្រ សងខាងផ្លូវ ហើយតំបន់ក្រៅគម្រោង ត្រូវបានជ្រើសរើសឆ្ងាយជាង ៥គីឡូម៉ែត្រ ពីសងខាងផ្លូវ ។ គេជ្រើសរើសដោយចៃដន្យ ៤៥០គ្រួសារ សម្រាប់តំបន់ក្នុងគម្រោង និង ៣៦០គ្រួសារ សម្រាប់តំបន់ក្រៅគម្រោង ។ ក្រុមស្រាវជ្រាវ បានប្រើអង្កេតគ្រួសារដើម្បីធ្វើវិភាគបែបពិពណ៌នាពីសូចនាករខាងដឹកជញ្ជូន និងខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង ។ ដោយសារទិន្នន័យមូលដ្ឋាននេះ នឹងត្រូវប្រើប្រាស់សម្រាប់តាមដាន និងវាយតម្លៃគម្រោង ដូច្នេះក្រុមស្រាវជ្រាវបានប្រើវិធីសាស្ត្រ PSM ដើម្បីកំណត់ពីលក្ខណៈសំគាល់ស្រដៀងគ្នានៃគំរូតាងទាំងពីរក្រុម និងកាត់បន្ថយលំអៀងបណ្តាលពីកំហុសក្នុងការជ្រើសរើសគំរូតាង ។ គ្រួសារដែលមិនស៊ីគ្នានឹងចរិតលក្ខណៈបានកំណត់ ត្រូវគេកាត់ចេញពីគំរូតាង ដើម្បីធ្វើឲ្យអថេរសម្រាប់វាស់វែងក្រុមទាំងពីរមានតុល្យភាព[៣] ។

---

១ អត្ថបទនេះរៀបរៀងដោយ លោក ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី លោក គឹម សុធន ជាអ្នកស្រាវជ្រាវ ហើយនិងលោក ឈឹម ឈន់ និងលោកស្រី ខៀវ ភិរម្យ ជាជំនួយការស្រាវជ្រាវនៅ CDRI ។ អត្ថបទនេះជាសេចក្តីសង្ខេបលទ្ធផលពិសោធន៍នៃគម្រោងមួយរបស់ CDRI គឺ ការវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃច្រករបៀងនៅតំបន់ឆ្នេរភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ ដែលធ្វើឡើងក្នុងឆ្នាំ២០០៩-១០ ក្រោមជំនួយហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ។

២ វិស័យអាទិភាពទាំង៩ គឺ វិស័យដឹកជញ្ជូន ទូរគមនាគមន៍ ថាមពល បរិស្ថាន ទេសចរណ៍ ការសម្របសម្រួលពាណិជ្ជកម្ម ការវិនិយោគ ការអភិវឌ្ឍន៍ធនធានមនុស្ស និងកសិកម្ម ។

៣ ព័ត៌មានលំអិត ស្តីពីវិធីសាស្ត្រស្រាវជ្រាវ មានចុះក្នុងឯកសាររបស់ Theng and Kem (ជិតបោះពុម្ពផ្សាយ) និង Hing et al. (ជិតបោះពុម្ពផ្សាយ) ។

## លទ្ធផលសំខាន់ៗបានពីពិសោធន៍

### ស្ថិតិបែបពិពណ៌នា

តារាង១ សង្ខេបពីភាពខុសប្លែកគ្នារវាងក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង តាមតម្លៃ t (t-value) របស់វា ។ t-value បង្ហាញថា មានភាពខុសប្លែកគ្នាច្រើនរវាងក្រុមទាំងពីរ ក្នុងលក្ខណៈសំគាល់ខាងប្រជាសាស្ត្រ និងសុខុមាលភាព ។ ភាពខុសប្លែកគ្នាខ្លាំងហាក់កើតមានចំពោះលក្ខណៈសំគាល់របស់មេគ្រួសារ ដែលមានភេទ អាយុ ស្ថានភាពមានប្ដីប្រពន្ធ កម្រិតអប់រំ ចំនួនឆ្នាំរស់នៅក្នុងតំបន់ កម្រិតប្រាក់ចំណូល អាជីវកម្មខ្នាតតូច និងចំពោះលក្ខណៈសំគាល់របស់គ្រួសារ ដែលមាន សន្ទស្សន៍ទ្រព្យសម្បត្តិ តម្លៃផ្ទះ និងទ្រព្យជាប់លាប់ ប្រាក់ចំណូលក្នុងមនុស្សម្នាក់ ចំណាយលើការប្រើប្រាស់ក្នុងមនុស្សម្នាក់ ចំណាយធ្វើកសិកម្ម និងចំណេញដុល ។ មានតែសូចនាករខាងប្រជាសាស្ត្រ និងជីវភាពពីរ-បីប៉ុណ្ណោះ ដែលគ្មានការខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិ ។ លទ្ធផលទាំងនេះបង្ហាញថា មានភាពលំអៀងខ្លះក្នុងការជ្រើសរើសគំរូតាង ទោះបីគំរូតាងត្រូវបានជ្រើសរើសដោយចៃដន្យក្ដី ។

### ក្រុមគ្រួសារក្រោយផ្ទៀងផ្ទាត់

ក្រុមស្រាវជ្រាវ បានប្រើវិធីសាស្ត្រ PSM ដើម្បីកាត់បន្ថយភាពលំអៀង និងបង្កើតលក្ខណៈសំគាល់ស្រដៀងគ្នានៃក្រុមក្នុងគម្រោង និងក្រៅគម្រោង សម្រាប់ការសិក្សាវាយតម្លៃពីផលប៉ះពាល់ទៅថ្ងៃអនាគត (Ravallion 2001, Caliendo & Kopeinig 2008, World Bank 2002) ។ តារាង២ បង្ហាញតួលេខប៉ាន់ស្មានបានពីការប្រើគំរូឡូហ្គីត (logit model) ដើម្បី

តារាង១៖ ការពិពណ៌នា និងភាពខុសប្លែកគ្នានៃអថេរ (មធ្យមក្នុងគំរូតាង)

| អថេរ | ក្នុងគម្រោង | ក្រៅគម្រោង | ភាពខុសប្លែក | T-value |
|---|---|---|---|---|
| *អថេរមិនឯករាជ្យ (គម្រោងធនាគារអភិវឌ្ឍន៍អាស៊ី)* | 1 | 0 | | |
| *អថេរសម្រាប់ប្រៀបធៀប* | | | | |
| ទំហំគ្រួសារ | 5.34 | 5.18 | 0.16 | 1.2 |
| ចំនួននារីអាយុ១៥-៤៥ឆ្នាំ | 1.36 | 1.33 | 0.03 | 0.4 |
| កម្លាំងពលកម្មគ្រួសារ | 4.15 | 3.96 | 0.19 | 1.6 |
| ចំនួនឆ្នាំរស់នៅក្នុងភូមិ | 4.53 | 3.39 | 1.14* | 1.8 |
| ភេទមេគ្រួសារ (លេខតំណាង 1=បុរស, 0=ស្ត្រី) | 0.76 | 0.84 | -0.08*** | -2.7 |
| អាយុមេគ្រួសារ | 50.80 | 46.69 | 4.12*** | 4.3 |
| អាយុមេគ្រួសារលើកជាការ៉េ | 2763.1 | 2358.2 | 404.9*** | 4.1 |
| ស្ថានភាពមានប្ដីប្រពន្ធរបស់មេគ្រួសារ(១=រៀបការ , 0= ផ្សេងទៀត) | 0.76 | 0.82 | -0.06** | -2.0 |
| កម្រិតអប់រំរបស់មេគ្រួសារ(ចំនួនឆ្នាំ) | 3.64 | 4.20 | -0.56** | -2.5 |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្ម | 100.96 | 67.50 | 33.46*** | 3.9 |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្មលើកជាការ៉េ | 27460.4 | 15691.6 | 11768.8** | 2.2 |
| ភាពអត់ការងារធ្វើ(១=អត់ការងារ, 0=មានការងារ) | 0.29 | 0.35 | -0.05 | -1.6 |
| មេគ្រួសារជាមន្ត្រីរាជការ | 0.063 | 0.056 | 0.008 | 0.5 |
| មេគ្រួសារជាពលករកសិដ្ឋាន | 0.079 | 0.095 | -0.016 | -0.8 |
| អាជីវកម្មខ្នាតតូចរបស់មេគ្រួសារ | 0.33 | 0.26 | 0.07** | 2.3 |
| ចំនួនសកម្មភាពមិនមែនកសិកម្មរបស់មេគ្រួសារ | 0.85 | 0.81 | 0.04 | 0.9 |
| សន្ទស្សន៍ទ្រព្យសម្បត្តិទាំងអស់របស់គ្រួសារ | 0.85 | -1.04 | 1.89*** | 14.8 |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុប | 377.5 | 440.4 | -62.9** | -2.0 |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុបលើកជាការ៉េ | 359788.1 | 343831.0 | 15957.1 | 0.2 |
| តម្លៃផ្ទះ | 1014.4 | 424.7 | 589.7*** | 4.4 |
| តម្លៃផ្ទះលើកជាការ៉េ | 7409425.0 | 395630.6 | 7013794.0 | 1.6 |
| *អថេរវាស់វែងលទ្ធផល ( ការប៉ះពាល់រំពឹងទុកនៃគម្រោងផ្លូវ)* | | | | |
| ប្រាក់ចំណូលប្រចាំថ្ងៃ/១នាក់(រៀល) | 3801.8 | 3218.9 | 582.9*** | 3.1 |
| ចំណាយលើអាហារប្រចាំថ្ងៃ/១នាក់(រៀល) | 2518.4 | 2372.0 | 146.4 | 1.6 |
| ចំណាយប្រើប្រាស់ប្រចាំថ្ងៃមិនមែនអាហារ/១នាក់(រៀល) | 1770.2 | 1503.2 | 267.0** | 2.0 |
| ចំណាយប្រើប្រាស់សរុបប្រចាំថ្ងៃ/១នាក់ | 4288.6 | 3875.2 | 413.3** | 2.2 |
| ចំណាយផលិតកម្មលើស្រូវ/១ហិកតា(ម៉ឺនរៀល) | 180.4 | 148.7 | 31.8*** | 2.7 |
| ចំណេញដុលលើស្រូវ/១ហិកតា(ម៉ឺនរៀល) | 52.9 | 71.1 | -18.2* | -1.7 |
| ចំណេញដុលមិនមែនស្រូវ/១ហិកតា(ម៉ឺនរៀល) | 90.84 | 153.5 | -62.7 | -1.4 |

Level of significance * at 10 percent; ** at 5 percent; *** at 1 percent.

*ប្រភព៖ អង្កេតគ្រួសារ ខែធ្នូ ២០០៩*

ផ្គូផ្គងគ្រួសារក្នុងតំបន់អនុវត្តគម្រោង GMS-SCC ជាមួយគ្រួសារក្រៅតំបន់គម្រោង ។ លទ្ធផលពីការផ្គូផ្គង បង្ហាញថា មានតែអថេរពីរ-បីប៉ុណ្ណោះ (កម្រិតអប់រំរបស់មេគ្រួសារ និងទ្រព្យសម្បត្តិ) ដែលមានសារៈសំខាន់ខាងស្ថិតិ ហើយរឿងនេះ បង្ហាញពីភាពស្រដៀងគ្នា រវាងគ្រួសារក្នុងតំបន់គម្រោង និងតំបន់ក្រៅគម្រោង ដែលបានផ្គូផ្គង ។

ក្រោយផ្គូផ្គងរួច ក្រុមស្រាវជ្រាវអាចរកឃើញគ្រួសារដែលត្រូវរក្សាទុក (on-support) និងគ្រួសារត្រូវជម្រុះចោល (off-support) ។ មាន ៩៨គ្រួសារ ក្នុងតំបន់គម្រោង ដែលត្រូវចាត់ចូលក្នុងក្រុមគ្រួសារត្រូវជម្រុះចោល ហើយ ៣៤៤គ្រួសារក្នុងតំបន់គម្រោង មានលក្ខណៈស៊ីគ្នាល្អជាមួយ ៣៥៩គ្រួសារនៅតំបន់ក្រៅគម្រោង ។ លក្ខណៈសំគាល់នៃគ្រួសារនានាដែលមិនអាចរកគូផ្គូផ្គងសមស្របបាន (ភាគច្រើនជាគ្រួសាររស់នៅតាមភូមិក្បែរព្រំដែន និងទីប្រជុំជន) ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានអគ្គិសនី ទឹកម៉ាស៊ីន ឬប្រភពថាមពលសម្រាប់ចំអិនអាហារដែលខ្ពស់ហួសលទ្ធភាពគ្រួសារនៅតំបន់ក្រៅគម្រោង ។

លទ្ធផលបានមកពីការផ្គូផ្គងគ្រួសារក្នុងតារាង៣ បង្ហាញថា ភាពខុសប្លែកគ្នារវាងសូចនាករលទ្ធផលរពឹងទុក បានថយចុះយ៉ាងច្រើន ហើយតុល្យភាពបានកើនឡើង ។ ក្រោយការផ្គូផ្គងលក្ខណៈសំគាល់នានា រួមមាន ប្រាក់ចំណូលក្នុងមនុស្សម្នាក់ ចំណាយប្រើប្រាស់មិនមែនអាហារក្នុងមនុស្សម្នាក់ ចំណាយប្រើប្រាស់សរុប ចំណាយលើផលិតកម្មស្រូវ និងចំណូលដុលពីស្រូវ បង្ហាញថា មិនមានគំលាតគួរកត់សំគាល់ខាងស្ថិតិខ្លាំងទេ ហើយ ចំណាយប្រើប្រាស់ជាអាហារក្នុងមនុស្សម្នាក់ និងចំណេញដុលមិនមែនបានពីស្រូវ មានតុល្យភាពកាន់តែប្រសើរឡើង ។

ការផ្គូផ្គងនេះ ត្រូវតែផ្ទៀងផ្ទាត់បញ្ជាក់ ព្រោះយើងមិនបានដាក់លក្ខខណ្ឌលើគ្រប់អថេរទេ គឺ គ្រាន់តែបានប្រើ propensity score ដើម្បីពិនិត្យមើលថា តើនីតិវិធីផ្គូផ្គងនេះអាចបង្កើតតុល្យភាពសម្រាប់របាយអថេរពាក់ព័ន្ធនានា រវាងក្រុមក្នុងតំបន់គម្រោង និងក្រុមក្នុងតំបន់ក្រៅគម្រោង ឬទេ ។ លំអៀងស្តង់ដារ Pseudo-R2 និង t-statistics នៅមុននិងក្រោយការផ្គូផ្គង អាចប្រើជាសូចនាករដ៏សំខាន់សម្រាប់ត្រួតពិនិត្យគុណភាពនៃការផ្គូផ្គង (Caliendo & Kopeinig 2008) ។ មេដ្យាន និងមធ្យមនៃលំអៀងស្តង់ដារ បានធ្លាក់ចុះច្រើន មកត្រឹម ២,៧% និង ៣,៨% រៀងគ្នា បន្ទាប់ពីការផ្គូផ្គង ។ Caliendo and Kopeining (2008) លើកឡើងថា មេដ្យាន និងមធ្យម នៃលំអៀងស្តង់ដារ

តារាង២៖ Propensity score សម្រាប់ការផ្គូផ្គងគ្រួសារ (ការប៉ាន់ស្មានដោយប្រើគំរូ logit)

| អថេរសម្រាប់ប្រៀបធៀប | មេគុណ | លំអៀងស្តង់ដារ | z |
|---|---|---|---|
| ទំហំគ្រួសារ | -0.0125 | 0.1243 | -0.10 |
| ចំនួននារីអាយុ ១៥-៤៥ឆ្នាំ | 0.0189 | 0.1294 | 0.15 |
| កម្លាំងពលកម្មគ្រួសារ | -0.0496 | 0.1725 | -0.29 |
| ចំនួនឆ្នាំរស់នៅក្នុងភូមិ | 0.0107 | 0.0129 | 0.82 |
| ភេទមេគ្រួសារ (១=ប្រុស 0=ស្រី) | -0.3322 | 0.3406 | -0.98 |
| អាយុមេគ្រួសារ | 0.1027 | 0.0547 | 1.88 |
| អាយុមេគ្រួសារលើកជាការ៉េ | -0.0007 | 0.0005 | -1.35 |
| ស្ថានភាពមានប្តីប្រពន្ធនៃមេគ្រួសារ (១=រៀបការ 0=ផ្សេងទៀត) | 0.5167 | 0.3415 | 1.51 |
| កម្រិតអប់រំរបស់មេគ្រួសារ (ចំនួនឆ្នាំ) | -0.0857 | 0.0332 | -2.58** |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្ម | 0.0024 | 0.0021 | 1.11 |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្មលើកជាការ៉េ | 0.0000 | 0.0000 | -1.42 |
| ភាពអត់ការងារធ្វើ (១= អត់ការងារ 0= មានការងារ) | 0.0122 | 0.3557 | 0.03 |
| មេគ្រួសារជាមន្ត្រីរាជការ | -0.5475 | 0.4511 | -1.21 |
| មេគ្រួសារជាពលករកសិដ្ឋាន | -0.1324 | 0.3437 | -0.39 |
| អាជីវកម្មខ្នាតតូចរបស់មេគ្រួសារ | -0.0465 | 0.2379 | -0.20 |
| ចំនួនសកម្មភាពមិនមែនកសិកម្មរបស់មេគ្រួសារ | 0.2633 | 0.2506 | 1.05 |
| សន្ទស្សន៍ទ្រព្យសម្បត្តិទាំងអស់របស់គ្រួសារ | 0.8939 | 0.0880 | 10.15*** |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុប | -0.0024 | 0.0006 | -3.96*** |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុបលើកជាការ៉េ | 0.0000 | 0.0000 | 2.04** |
| តម្លៃផ្ទះ | 0.0003 | 0.0003 | 0.85 |
| តម្លៃផ្ទះលើកជាការ៉េ | 0.0000 | 0.0000 | 0.35 |
| អញ្ញត្តិថេរ (Constant) | -2.0159 | 1.3431 | -1.50 |
| ចំនួនសង្កេតឃើញ | 801 | - | - |
| Pseudo-$R^2$ | 0.29 | - | - |

*Level of significance * at 10 percent; * * at 5 percent; * * * at 1 percent.*

តារាង៣៖ ការប្រៀបធៀបអថេរវាស់វែងលទ្ធផល ក្រោយផ្គូផ្គងរួច (គិតតាមថ្លៃថេរប្រាក់រៀល ខែធ្នូ ២០០៩)

| អថេរវាស់វែងលទ្ធផល | ភាពខុសប្លែកគ្នា (ផ្គូផ្គងមិនស៊ីគ្នា) | | ភាពខុសប្លែកគ្នា (ផ្គូផ្គងស៊ីគ្នា) | |
|---|---|---|---|---|
| | ផ្គូផ្គងមិនស៊ីគ្នា | T-stat | ផ្គូផ្គងស៊ីគ្នា | T-stat |
| ប្រាក់ចំណូលគិតក្នុងមនុស្សម្នាក់ | 582.87 | 3.08 * * * | -86.53 | -0.40 |
| ចំណាយប្រើប្រាស់ជាអាហារក្នុងមនុស្សម្នាក់ | 146.37 | 1.65 | 64.52 | 0.63 |
| ចំណាយប្រើប្រាស់មិនមែនអាហារក្នុងមនុស្សម្នាក់ | 266.98 | 1.95 * * | 43.22 | 0.25 |
| ចំណាយប្រើប្រាស់សរុបក្នុងមនុស្សម្នាក់ | 413.34 | 2.2 * * | 107.74 | 0.48 |
| ចំណាយលើផលិតកម្មស្រូវ/ហិកតា (ម៉ឺនរៀល) | 31.77 | 2.74 * * * | 15.94 | 1.22 |
| ចំណេញដុលពីស្រូវ/ហិកតា (ម៉ឺនរៀល) | -18.24 | -1.75 * | -7.10 | -0.51 |
| ចំណេញដុលមិនមែនបានពីស្រូវ/ហិកតា (ម៉ឺនរៀល) | -62.67 | -1.35 | -39.01 | -0.73 |

*Level of significance * at 10 percent; * * at 5 percent; * * * at 1 percent.*

ក្រោម ៣% និង ៥% ក្រោយការផ្គូផ្គង មានន័យថា ភាពស៊ីគ្នានៃរបាយអថេរអាចជឿជាក់បាន ។ pseudo-R2 បានពីការប៉ាន់ស្មាន propensity score ក្រោយការផ្គូផ្គង មានកម្រិតទាបជាខ្លាំង (0,0៣%) ធៀបនឹងតម្លៃមុនការផ្គូផ្គង (0,២៩%) ហើយតម្លៃ P-value នៃការធ្វើតេស្តអត្រាជីវភាព ពុំមានគំលាតខ្ពស់ទេ (non-significant) ក្រោយការផ្គូផ្គង ដែលបង្ហាញថាមិនមានភាពខុសប្លែកគ្នាជាលក្ខណៈប្រព័ន្ធទេ ក្នុងរបាយនៃអថេរពាក់ព័ន្ធនានារវាងក្រុមទាំងពីរ ។ លទ្ធផលទាំងនេះបង្ហាញថា លំអៀងក្នុងការជ្រើសរើស បានថយចុះយ៉ាងច្រើនតាមរយៈការផ្គូផ្គងគ្រួសារ ហើយគំរូតាងស្រដៀងគ្នាពីរក្រុម ក៏ត្រូវបានបង្កើតឡើងសម្រាប់តាមដាន និងវាយតម្លៃ ។ តាមនេះ ៩៨គ្រួសារក្នុងតំបន់គំរោង ដែលមានលក្ខណៈមិនស៊ីគ្នាខ្លាំង ត្រូវបានកាត់ចេញ ធ្វើឲ្យយើងទទួលបានគំរូតាងសរុបចំនួន ៧០៣គ្រួសារក្រោយការផ្គូផ្គង ។

## សេចក្តីសន្និដ្ឋាន

របាយការណ៍នេះ បង្ហាញនូវសូចនាករមូលដ្ឋានមួយចំនួននៃតំបន់សិក្សាដែលមានសក្តានុពលមួយ នៅតាមខ្សែបណ្តោយគម្រោង GMS-SCC នៅកម្ពុជា ។ វាក៏បានផ្តល់នូវសូចនាករអំពីភាពស្រដៀងគ្នា និងភាពខុសប្លែកគ្នា នៃលក្ខណៈសំគាល់ក្រុមគ្រួសារ ក្នុងតំបន់អនុវត្តគម្រោង និងក្រៅតំបន់គម្រោងមុនការផ្គូផ្គង និងការថយចុះយ៉ាងច្រើននៃភាពខុសប្លែកគ្នាទាំងនោះ បន្ទាប់ពីធ្វើការផ្គូផ្គងរួច ។ មុនការផ្គូផ្គង យើងឃើញមានភាពខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិ ក្នុងសូចនាករខាងប្រជាសាស្ត្រ និងសុខុមាលភាព ដែលបង្ហាញពីភាពលំអៀងមួយចំនួនក្នុងការជ្រើសរើសគំរូតាងគ្រួសារ ។

គ្រួសារផ្គូផ្គងស៊ីគ្នា មានលក្ខណៈសំគាល់ស្រដៀងគ្នាក្នុងអថេរ ដែលមានតាំងពីសូចនាករភូមិសាស្ត្រ រហូតដល់សូចនាករសេដ្ឋកិច្ច-សង្គមកិច្ច និងសូចនាករមធ្យោបាយដឹកជញ្ជូន ។ ដោយប្រើវិធីសាស្ត្រ PSM យើងកសាងបានក្រុមគំរូតាងពីរ មានលក្ខណៈសំគាល់ស្រដៀងគ្នា ពោលគឺ ក្រុមក្នុងតំបន់អនុវត្តគម្រោងមាន ៣៤៤គ្រួសារ និងក្រុមក្នុងតំបន់ក្រៅគម្រោងមាន ៣៥៩គ្រួសារ ។ ម្យ៉ាងទៀត មាន ៩៨ គ្រួសារត្រូវបានកាត់ចេញពីក្រុមគំរូតាងក្នុងតំបន់គម្រោង ដោយសារមិនអាចរកគូផ្គូផ្គង ដែលមានលក្ខណៈសំគាល់ស៊ីគ្នាក្នុងក្រុមក្រៅគម្រោងបាន ។ ការជម្រុះនេះ អាចជួយសំចៃចំណាយ និងពេលវេលា ព្រមទាំងសម្រួលការប៉ាន់ស្មានពីផលប៉ះពាល់នៃគម្រោង ដើម្បីបង្កើនប្រសិទ្ធភាពការងារតាមដាន និងវាយតម្លៃ ។

## ឯកសារយោង


Caliendo, M. & S. Kopeinig (2008), "Some Practical Guidance for the Implementation of Propensity Score Matching", *Journal of Economic Surveys*, Vol. 22, No. 1, pp. 31 – 72

Ravallion, M. (2001), "The Mystery of the Vanishing Benefits: An Introduction to Impact Evaluation", *World Bank Economic Review*, Vol. 15, pp. 115 – 140

Theng Vuthy & Kem Sothorn, (forthcoming), The Importance of PSM in Evaluation Studies: A Case Study of Physical Infrastructure in Cambodia, Working Paper (Phnom Penh: CDRI)

World Bank (2002), Socioeconomic Impact Assessment of Rural Roads: Methodology and Questionnaires

Hing Vutha, Saing Chan Hang & Khieng Sothy, (forthcoming). Using Propensity Score Matching to Generate Two Comparable Groups in the Baseline Survey: The Case of GMS Transmission Line Project. Annual Development Review 2010/2011(Phnom Penh: CDRI).